**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខៈ ០២៤៤៥ ប្រក

# ប្រកាស
# ស្តីពី
# ការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅ
# របស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃព្រហស្បតិ៍ ១រោច ខែបឋមាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងប្រកាសលេខ ១៩១២ ប្រ.ក ចុះថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- យោងតាមសំណើរបស់អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

## សម្រេច

**ប្រការ១.-**

ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ស្ថិតនៅក្រោមឱវាទអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងស្ថិតនៅក្រោមការបញ្ជាដឹកនាំជំនាញរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ មានសមត្ថកិច្ចការពារ និងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជូនប្រជាពលរដ្ឋនៅក្នុងរាជធានី ខេត្ត ។

**ប្រការ២.-**

ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានភារកិច្ច ដូចខាងក្រោម ៖

-អនុវត្តការងាររក្សាសន្តិសុខ សុវត្ថិភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ការពារអាយុជីវិត សិទ្ធិ សេរីភាព កិត្តិយស សេចក្តីថ្លៃថ្នូរ ទ្រព្យសម្បត្តិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន

-ការពារសុវត្ថិភាពថ្នាក់ដឹកនាំជាតិ-អន្តរជាតិ និងភ្ញៀវបរទេស

-ការពារការសម្ងាត់ជាតិ ការពារស្ថាប័ន សម្បត្តិវប្បធម៌ បេតិកភណ្ឌជាតិ ទ្រព្យសម្បត្តិសាធារណៈ និងគោលដៅសំខាន់ៗ

-រៀបចំសណ្តាប់ធ្នាប់សាធារណៈ សណ្តាប់ធ្នាប់ចរាចរផ្លូវគោក ផ្លូវទឹក ផ្លូវដែក និងការងារបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ

-ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពជួញដូរមនុស្ស អាជីវកម្មផ្លូវភេទលើនីតិជន អនីតិជន និងអំពើហិង្សាក្នុងគ្រួសារតាមនីតិវិធី

-ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀនក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ

-ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង និងបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ បទល្មើសបច្ចេកវិទ្យា និងល្បែងស៊ីសងខុសច្បាប់ ព្រមទាំងបទល្មើសផ្សេងៗទៀតដែលប្រឆាំងនឹងសន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គម

-ចាត់វិធានការគ្រប់គ្រងសកម្មភាពក្រុមហ៊ុនផ្តល់សេវាសន្តិសុខ

-ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើវិច្ឆេទកម្មសេដ្ឋកិច្ច និងបង្ក្រាបបទល្មើសសេដ្ឋកិច្ចគ្រប់ប្រភេទ

-ធ្វើការងារបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ

-ចាត់វិធានការគ្រប់គ្រងមុខសញ្ញាល្មើសច្បាប់នានាក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ

-ចុះបញ្ជី និងគ្រប់គ្រងស្ថិតិ អាវុធ គ្រឿងផ្ទុះ ជាតិងាយឆេះ ជាតិពុល អាស៊ីដខ្លាំង និងមុខរបរដែលងាយប៉ះពាល់ដល់សន្តិសុខសង្គម

-ធ្វើការងារស្រាវជ្រាវប្រមូលព័ត៌មាន បង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពបង្កចលាចលសង្គម និងសកម្មភាពភេរវកម្ម

-ចាប់ខ្លួន ឃាត់ខ្លួនបណ្តោះអាសន្ន រៀបចំ និងបញ្ជូនសំណុំរឿង ជនល្មើស ព្រមទាំងវត្ថុតាងទៅអយ្យការតាមច្បាប់

-អនុវត្ត និងសហការអនុវត្តសាលក្រម សាលដីកា និងដីកានានារបស់ស្ថាប័នអយ្យការ និងតុលាការ

-សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ អនុវត្តវិធានការបង្ការ ទប់ស្កាត់គ្រោះមហន្តរាយផ្សេងៗ

-តាមដានការចុះបញ្ជីការស្នាក់នៅរបស់ប្រជាជន និងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន

-ធ្វើការងារគ្រប់គ្រងជនបរទេសមិនមែនអន្តោប្រវេសន្ត ជនបរទេសអន្តោប្រវេសន្ត និងជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជនក្នុងភូមិសាស្ត្រទទួលខុសត្រូវ

-ស្រាវជ្រាវរកមនុស្សបាត់ខ្លួន

-គ្រប់គ្រង បញ្ជា ដឹកនាំមន្ត្រីការិយាល័យជំនាញ អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ វរសេនាតូចនគរបាលការពារព្រំដែនគោក ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងប៉ុស្តិ៍នគរបាលការពារព្រំដែនគោក

-គ្រប់គ្រងចលនទ្រព្យ និងអចលនទ្រព្យរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

-ធ្វើការងាររដ្ឋបាល បុគ្គលិក បណ្តុះបណ្តាល និងការងារគេស្ករ គណនេយ្យរបស់ស្នងការដ្ឋាននគរ-បាលរាជធានី ខេត្តតាមការកំណត់

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្តតាមការកំណត់

-បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិប្រគល់ឲ្យ ។

**ប្រការ៣..**

ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

**ក- ផែនការងារធនធានមនុស្ស**

១- ការិយាល័យបុគ្គលិក

២- ការិយាល័យបណ្តុះបណ្តាល

៣- ការិយាល័យផ្សព្វផ្សាយអប់រំ

**ខ- ផែនការងារសេនាធិការ**

១- ការិយាល័យរដ្ឋបាល

២- ការិយាល័យសរុប ផែនការ

៣- ការិយាល័យវិទ្យុទាក់ទង

៤- ការិយាល័យអក្សរសម្ងាត់

៥- ការិយាល័យកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល

៦- ការិយាល័យអន្តរាគមន៍ និងតម្រួតបទបញ្ជា

**គ- ផែនការងារនគរបាលព្រហ្មទណ្ឌ**

១- ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់

២- ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល

៣- ការិយាល័យនគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ

**ឃ- ផែនការងារនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច**

- ការិយាល័យនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច

**ង- ផែនការងារប្រឆាំងគ្រឿងញៀន**

- ការិយាល័យប្រឆាំងគ្រឿងញៀន

**ច- ផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រ**

- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

**ឆ- ផែនការងារសន្តិសុខ**

១- ការិយាល័យសន្តិសុខផ្ទៃក្នុង

២- ការិយាល័យប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន

៣- ការិយាល័យគ្រប់គ្រងសន្តិសុខឯកជន (លើកលែងខេត្តរតនគិរី និងខេត្តឧត្តរមានជ័យ)

៤- ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា (មាននៅរាជធានីភ្នំពេញ ខេត្តសៀមរាប ស្វាយរៀង និងខេត្តព្រះសីហនុ)

៥- ការិយាល័យអង្គរក្ស (មាននៅស្នងការដ្ឋាននគរបាលខេត្តសៀមរាប)

ជ- ផែនការងារនគរបាលសណ្តាប់ធ្នាប់

១- ការិយាល័យនគរបាលសណ្តាប់ធ្នាប់

២-ការិយាល័យនគរបាលទេសចរណ៍ (លើកលែងខេត្តកំពង់ឆ្នាំង ព្រៃវែង ស្វាយរៀង ប៉ៃលិន សៀមរាប និងខេត្តត្បូងឃ្មុំ)

៣-ការិយាល័យនគរបាលការពារបេតិកភណ្ឌ (មាននៅរាជធានីភ្នំពេញ ខេត្តតាកែវ កំពង់ធំ បាត់ដំបង សៀមរាប ឧត្តរមានជ័យ និងខេត្តព្រះវិហារ)

៤- ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក

៥- ការិយាល័យនគរបាលចរាចរណ៍ផ្លូវទឹក (លើកលែងខេត្តកំពង់ស្ពឺ ស្វាយរៀង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ មណ្ឌលគិរី និងខេត្តរតនគិរី )

*+ ដោយឡែក នៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ផែនការងារនគរបាលសណ្តាប់ធ្នាប់ បំបែកជា០២ផែនគឺ ៖*

១- ផែនការងារនគរបាលសណ្តាប់ធ្នាប់ ដែលមានការិយាល័យចំណុះចំនួន០៣ គឺ ៖

- ការិយាល័យនគរបាលសណ្តាប់ធ្នាប់
- ការិយាល័យនគរបាលទេសចរណ៍
- ការិយាល័យនគរបាលការពារបេតិកភណ្ឌ

២- ផែនការងារនគរបាលចរាចរណ៍ ដែលមានការិយាល័យចំណុះចំនួន០២ គឺ ៖

- ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក
- ការិយាល័យនគរបាលចរាចរណ៍ផ្លូវទឹក

ឈ- ផែនការងារគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងអគ្គិភ័យ

១- ការិយាល័យនគរបាលបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ

២-ការិយាល័យគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងជាតិពុល

ញ- ផែនការងារអន្តោប្រវេសន៍

១- ការិយាល័យគ្រប់គ្រងជនបរទេស

២- ការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី

ដ- ផែនការងារអត្តសញ្ញាណកម្ម

១- ការិយាល័យគ្រប់គ្រងការស្នាក់នៅ

២-ការិយាល័យអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

ឋ- ផែនការងារភស្តុភារ និងហិរញ្ញវត្ថុ

១-ការិយាល័យភស្តុភារ

២-ការិយាល័យគណនេយ្យ

៣-ការិយាល័យសុខាភិបាល

ឌ- ផែននគរបាលការពារព្រំដែនគោក (មាននៅស្នងការដ្ឋាននគរបាលខេត្តជាប់ព្រំដែន និងលើកលែងស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ និងវរសេនាតូចនគរបាលអន្តរាគមន៍ ដែលចំណុះនាយកដ្ឋាននគរបាលការពារព្រំដែនគោក) ។

ឍ- អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ។

ណ- ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ។

**ប្រការ៤..**

តួនាទី និងភារកិច្ចរបស់ការិយាល័យ ចំណុះផែនការងារនីមួយៗមានដូចខាងក្រោម ៖

**ក- ផែនការងារធនធានមនុស្ស**

**១- ការិយាល័យបុគ្គលិក** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារបុគ្គលិក ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ វិធានការលើការងារធនធានមនុស្ស និងរចនាសម្ព័ន្ធរបស់ស្នងការដ្ឋាន
- អនុវត្តវិធានការជំនាញគ្រប់គ្រងមន្ត្រីនគរបាលជាតិរបស់ស្នងការដ្ឋាន
- កសាងផែនការក្រុបខ័ណ្ឌមន្ត្រីនគរបាលជាតិស្របតាមការប្រែប្រួលអំពីភារកិច្ច និងរចនាសម្ព័ន្ធ
- លើកសំណើសុំគោលការណ៍តែងតាំងមុខតំណែង ឋានន្តរសក្តិ ដំឡើងឋានៈ ឋានន្តរសក្តិ ការផ្ទេរផ្លាស់ប្តូរភារកិច្ច ការលើកសរសើរជូនរង្វាន់ ការដាក់វិន័យ ការដាក់ឲ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ការដាក់ឲ្យនៅក្នុងភាពទំនេរគ្មានបៀវត្ស ការអនុញ្ញាតច្បាប់ឈប់សម្រាក ការលុបឈ្មោះចេញពីក្របខ័ណ្ឌ ការដាក់ឲ្យចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ និងគោលនយោបាយធានារ៉ាប់រងសង្គមតាមបែបបទ និងនីតិវិធី
- ពិនិត្យផ្ទៀងផ្ទាត់បញ្ជីឈ្មោះក្នុងតារាងទូទាត់ប្រាក់បៀវត្សប្រចាំខែរបស់មន្ត្រីនគរបាលជាតិ
- សិក្សាអំពីបុគ្គលិកលក្ខណៈ ឧបនិស្ស័យ សមត្ថភាព មុខជំនាញឯកទេសដែលបានបណ្តុះបណ្តាល បទពិសោធន៍ គំនិតផ្តួចផ្តើមរបស់មន្ត្រីនគរបាលជាតិបម្រើគោលដៅបន្តវេន
- រៀបចំការងារគ្រប់គ្រងស្ថិតិទិន្នន័យបុគ្គលិក តារាងព្រឹត្តបត្រពិន្ទុ និងទុកដាក់ថែរក្សាសំណុំលិខិតឯកត្តជនមន្ត្រីនគរបាលជាតិតាមប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំក្រុមប្រឹក្សាវិន័យ និងក្រុមប្រឹក្សាប្រឡងប្រណាំងរបស់នគរបាលជាតិតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យបណ្តុះបណ្តាល** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារបណ្តុះបណ្តាល ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារបណ្តុះបណ្តាល
- កសាងផែនការបណ្តុះបណ្តាលមន្ត្រីនគរបាលជាតិតាមការកំណត់
- ស្រាវជ្រាវធ្វើទំនើបកម្មខ្លឹមសារឯកសារបង្ហាត់បង្រៀន និងកម្មវិធីបណ្តុះបណ្តាល
- លើកសំណើចាត់បញ្ជូនមន្ត្រីនគរបាលជាតិសិក្សាវគ្គបណ្តុះបណ្តាល វគ្គបំប៉ន និងសិក្ខាសាលាក្នុង និងក្រៅប្រទេសតាមការកំណត់
- រៀបចំបើកវគ្គបណ្តុះបណ្តាលបំប៉នរយៈពេលខ្លីនៅនឹងកន្លែង
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

៣- **ការិយាល័យផ្សព្វផ្សាយអប់រំ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារផ្សព្វផ្សាយអប់រំ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារផ្សព្វផ្សាយអប់រំ
- ធ្វើការងារផ្សព្វផ្សាយអប់រំដល់មន្ត្រីក្រោមឱវាទស្នងការដ្ឋាន ដើម្បីជានាការអនុវត្តមុខវិជ្ជាជីវៈសារព័ត៌មាន
- ចាត់វិធានការជំនាញអប់រំសតិអារម្មណ៍ប្រជាពលរដ្ឋ ដើម្បីចូលរួមគាំទ្រកិច្ចប្រតិបត្តិការគ្រប់មុខជំនាញរបស់នគរបាលជាតិ
- ផ្សព្វផ្សាយព័ត៌មានតាមរយៈទស្សនាវដ្តី នាទីសន្តិសុខមាតុភូមិ គេហទំព័រ បណ្តាញសង្គម អំពីសមិទ្ធផលនានា និងការរីកចម្រើនរបស់សង្គមជាតិ ដែលឆ្លុះបញ្ចាំងពីសកម្មភាព និងស្នាដៃរបស់រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ មន្ត្រីនគរបាលជាតិ ស្របតាមវិជ្ជាជីវៈសារព័ត៌មាន
- ប្រមូល ចងក្រងនូវឯកសារ លិខិតបទដ្ឋានគតិយុត្ត សមិទ្ធផល ស្នាដៃជាប្រវត្តិសាស្ត្រនានារបស់នគរបាលជាតិកម្ពុជាគ្រប់ជំនាន់ ដើម្បីរៀបចំទុកដាក់ ថែរក្សាក្នុងបណ្ណាល័យ
- ពង្រឹងសមត្ថភាពមន្ត្រីជំនាញផ្សព្វផ្សាយអប់រំ អំពីជំនាញវិជ្ជាជីវៈសារព័ត៌មាន
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ខ- ផែនការងារសេនាធិការ**

១- **ការិយាល័យរដ្ឋបាល** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងាររដ្ឋបាល និងបញ្ជូនបញ្ជារបស់ស្នងការទៅអង្គភាពក្រោមឱវាទ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងាររបៀប និងទំនាក់ទំនងសាធារណៈ
- ធ្វើការងាររបៀប ទទួល និងបញ្ជូនលិខិតចេញ ចូលទៅតាមជំនាញតាមការកំណត់
- រៀបចំការប្រជុំ កន្លែងធ្វើការ ពិធីការ និងការងារអនាម័យរបស់ស្នងការដ្ឋាន
- តាមដានត្រួតពិនិត្យការអនុវត្តបទបញ្ជា សារាចរ សេចក្តីណែនាំផ្សេងៗ
- ស្រាវជ្រាវរៀបចំកសាងលិខិតបទដ្ឋាន បទបញ្ជាផ្ទៃក្នុង និងរបៀបរបបការងារជូនស្នងការពិនិត្យសម្រេច
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

២- **ការិយាល័យសរុប ផែនការ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារសរុប ផែនការ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់កសាងផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងទិសដៅការងាររបស់ស្នងការដ្ឋាន
- ប្រមូលរបាយការណ៍ បូកសរុប វិភាគព័ត៌មានសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម និងលទ្ធផលកិច្ចប្រតិបត្តិការរបស់នគរបាលជាតិដើម្បីមានវិធានការ
- ផ្សព្វផ្សាយ និងតាមដានការអនុវត្តផែនការសកម្មភាពរបស់ស្នងការដ្ឋាន ព្រមទាំងបូកសរុបដកពិសោធន៍កិច្ចប្រតិបត្តិការ
- ណែនាំតាមដានត្រួតពិនិត្យ និងបូកសរុបការអនុវត្តគោលនយោបាយ (ភូមិ ឃុំមានសុវត្ថិភាព)

- គ្រប់គ្រង និងដំណើរការប្រព័ន្ធកត់ត្រាទិន្នន័យរបស់ស្នងការដ្ឋាន
- រៀបចំចងក្រងទុកដាក់តំកល់ និងថែរក្សាឯកសារតាមគោលការណ៍បច្ចេកទេស
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៣- ការិយាល័យវិទ្យុទាក់ទង** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារវិទ្យុទាក់ទង ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារវិទ្យុទាក់ទង
- គ្រប់គ្រង និងប្រើប្រាស់វិទ្យុទាក់ទងដើម្បីកិច្ចប្រតិបត្តិការ
- អនុវត្តការងារបញ្ជូនទទួលព័ត៌មានតាមគ្រប់មធ្យោបាយរវាងស្នងការដ្ឋានជាមួយអង្គភាពក្រោមឱវាទ
- តាមដានការបម្រែបម្រួលនៃទំនាក់ទំនង និងមានវិធានការ ដើម្បីធានាប្រសិទ្ធភាព សុវត្ថិភាព និងនិរន្តរភាពនៃដំណើរការបញ្ជូនទទួលព័ត៌មាន
- ចុះបញ្ជីគ្រប់គ្រង និងបែងចែកព័ត៌មានទៅតាមអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ និងវរសេនាតូចនគរបាលការពារព្រំដែនគោក
- លើកគម្រោងប្រើប្រាស់ និងថែទាំជួសជុលវិទ្យុគមនាគមន៍គ្រប់ប្រភេទរបស់ស្នងការដ្ឋាន
- ប្រចាំការ២៤ម៉ោង ដើម្បីទទួលព័ត៌មានទាន់ហេតុការណ៍ពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធដល់សន្តិសុខសណ្ដាប់ធ្នាប់សង្គម
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៤- ការិយាល័យអក្សរសម្ងាត់** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារអក្សរសម្ងាត់ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារអក្សរសម្ងាត់
- ទទួល និងបញ្ជូនសារទូរលេខសម្ងាត់ទៅស្ថាប័ន អង្គភាពពាក់ព័ន្ធ
- បាំងសារទូរលេខសម្ងាត់ ប្រែសារទូរលេខសម្ងាត់ប្រព័ន្ធទាក់ទងអក្សរសម្ងាត់របស់ស្នងការដ្ឋាន
- លើកគម្រោងប្រើប្រាស់ និងថែទាំជួសជុលសម្ភារបរិក្ខារ និងម៉ាស៊ីនសារទូរលេខសម្ងាត់
- ចុះបញ្ជី និងរក្សាទុកសារទូរលេខសម្ងាត់
- បញ្ជូនសារទូរលេខសម្ងាត់តាមប្រព័ន្ធអ៊ីនធឺណែត អ៊ីម៉ែល ទូរសារ និងប្រៃសណីយ៍ទូរគមនាគមន៍
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៥- ការិយាល័យកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល
- គ្រប់គ្រង ដឹកនាំ ណែនាំមន្ត្រីប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ អំពីកិច្ចការនគរបាល និងសហគមន៍
- កសាងផែនការ និងរបៀបរបបធ្វើការងាររបស់នគរបាល និងសហគមន៍ស្របតាមតួនាទី ភារកិច្ចតាមការកំណត់
- ទំនាក់ទំនង និងសហការជាមួយរដ្ឋបាលដែនដី សមត្ថកិច្ចពាក់ព័ន្ធ និងសហគមន៍ ក្នុងការក្ដាប់សភាពការណ៍ក្នុងមូលដ្ឋាន ដើម្បីបម្រើការងារជំនាញ
- កត់ត្រាទិន្នន័យព័ត៌មានមន្ត្រីប៉ុស្តិ៍នគរបាលរដ្ឋបាលដើម្បីបម្រើផែនការបណ្ដុះបណ្ដាល បំប៉នជំនាញ
- ណែនាំតាមដានត្រួតពិនិត្យការងារគ្រប់គ្រង និងថែរក្សាអគារទីស្នាក់ការរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់
- ក្ដាប់សំណូមពរពីប្រជាពលរដ្ឋ សហគមន៍ សហគ្រាស គ្រឹះស្ថានសិក្សា វត្តអារាម ដើម្បីមានវិធានការដោះស្រាយ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៦- ការិយាល័យអន្តរាគមន៍ និងតម្រួតបទបញ្ជា** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារអន្តរាគមន៍ និងតម្រួតបទបញ្ជា ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារអន្តរាគមន៍ និងតម្រួតបទបញ្ជា
- ចាត់វិធានការអន្តរាគមន៍បង្ការ និងបង្ក្រាបសកម្មភាពភេរវកម្ម ការធ្វើបាតុកម្ម កុប្បកម្មខុសច្បាប់ ដែលបង្កមហន្តរាយដល់សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម
- សហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធអនុវត្តវិធានការបង្ការទប់ស្កាត់គ្រោះមហន្តរាយ ដើម្បីការពារទ្រព្យសម្បត្តិសាធារណៈ អាយុជីវិត និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ
- ត្រៀមមធ្យោបាយសម្ភារ ឧបករណ៍បច្ចេកទេស អាវុធយុទ្ធភ័ណ្ឌ និងចល័តកម្លាំងប្រចាំការការពារសន្តិសុខ សុវត្ថិភាពគណៈប្រតិភូតាមគោលដៅ
- លើកគម្រោងផែនការ និងចាត់វិធានការជំនាញការពារបណ្ដាគោលដៅសំខាន់ៗតាមការកំណត់
- អនុវត្តវិធានការជំនាញយាមប្រចាំការ ត្រួតពិនិត្យឆែកឆេរ និងរៀបចំសណ្ដាប់ធ្នាប់លើមធ្យោបាយ និងមនុស្សចេញចូលគោលដៅក្នុងសមត្ថកិច្ចទទួលខុសត្រូវ
- ល្បាតចល័តការពារនៅតាមគោលដៅសំខាន់ៗ និងធ្វើអន្តរាគមន៍នៅទីកន្លែងដែលមានមនុស្សតវ៉ាការធ្វើបាតុកម្ម និងការសម្ដែងមតិនៅទីសាធារណៈ ដើម្បីធានាសន្តិសុខសណ្ដាប់ធ្នាប់
- សហការជាមួយអង្គភាពពាក់ព័ន្ធត្រៀមកម្លាំងចាត់វិធានការចាំបាច់ដើម្បីសង្គ្រោះប្រជាពលរដ្ឋដែលជួបគ្រោះមហន្តរាយផ្សេងៗ
- ផ្សព្វផ្សាយ និងតាមដានត្រួតពិនិត្យការអនុវត្តក្រមសីលធម៌ បទកំណត់ បទបញ្ជា លិខិតបទដ្ឋានគតិយុត្តនានា ដើម្បីលើកកម្ពស់សីលធម៌ គុណធម៌ កិត្តិយស សេចក្ដីថ្លៃថ្នូររបស់នគរបាលជាតិ

- ហ្វឹកហ្វឺនមុខជំនាញរបៀប សណ្តាប់ធ្នាប់កងជួរ និងយុទ្ធសាស្ត្របុគ្គលដល់មន្ត្រីនគរបាលជាតិ
- រៀបចំទទួលបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំជាតិ និងអន្តរជាតិ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**គ- ផែនការងារនគរបាលព្រហ្មទណ្ឌ**

**១- ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារព្រហ្មទណ្ឌកម្រិតធ្ងន់ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារព្រហ្មទណ្ឌកម្រិតធ្ងន់
- ចាត់វិធានការជំនាញបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសឧក្រិដ្ឋ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ
- ស៊ើបអង្កេតស្រាវជ្រាវបទល្មើស ចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួនបណ្តោះអាសន្ន រៀបចំ និងបញ្ជូនសំណុំរឿង ជនសង្ស័យ ព្រមទាំងវត្ថុតាងទៅអយ្យការតាមច្បាប់
- អនុវត្ត និងសហការអនុវត្តសាលក្រម សាលដីកា និងដីកានានារបស់ស្ថាប័នអយ្យការ និងតុលាការ
- ប្រើប្រាស់វិធីសាស្ត្រជំនាញតាមដានស្រាវជ្រាវស៊ើបបញ្ជាក់កំណត់អត្តសញ្ញាណ ប្រវត្តិសកម្មភាពរបស់ជនសង្ស័យល្មើសច្បាប់
- រៀបចំវិធីសាស្ត្របង្ការទប់ស្កាត់ និងបង្ក្រាបបទឧក្រិដ្ឋតាមក្រមនីតិវិធីព្រហ្មទណ្ឌ
- ស៊ើបអង្កេតបឋម និងអនុវត្តដីកាចាត់ឲ្យសាកសួរជំនួស ក្នុងករណីបទល្មើសជាក់ស្តែងតាមនីតិវិធីព្រហ្មទណ្ឌ
- រៀបចំការងារទទួលពាក្យបណ្តឹង ធ្វើកំណត់ហេតុ និងសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធចុះពិនិត្យកន្លែងកើតហេតុប្រមូលព័ត៌មាន សម្ភារ វត្ថុតាង និងកំណត់អត្តសញ្ញាណជនសង្ស័យ
- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារព្រហ្មទណ្ឌកម្រិតស្រាល ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារព្រហ្មទណ្ឌកម្រិតស្រាល
- ចាត់វិធានការជំនាញបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសមជ្ឈិមស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ
- ស៊ើបអង្កេតស្រាវជ្រាវបទល្មើស ចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួនបណ្តោះអាសន្ន រៀបចំ និងបញ្ជូនសំណុំរឿង ជនសង្ស័យ ព្រមទាំងវត្ថុតាងទៅអយ្យការតាមច្បាប់
- អនុវត្ត និងសហការអនុវត្តសាលក្រម សាលដីកា និងដីកានានារបស់ស្ថាប័នអយ្យការ និងតុលាការ
- ប្រើប្រាស់វិធីសាស្ត្រជំនាញតាមដានស្រាវជ្រាវស៊ើបបញ្ជាក់កំណត់អត្តសញ្ញាណ ប្រវត្តិសកម្មភាពរបស់ជនសង្ស័យល្មើសច្បាប់

- រៀបចំវិធីសាស្ត្របង្ការទប់ស្កាត់ និងបង្ក្រាបបទមជ្ឈឹមតាមក្រមនីតិវិធីព្រហ្មទណ្ឌ
- ស៊ើបអង្កេតបឋម និងអនុវត្តដីកាចាត់ឲ្យសាកសួរជំនួស ក្នុងករណីបទល្មើសជាក់ស្តែងតាមនីតិវិធីព្រហ្មទណ្ឌ
- រៀបចំការងារទទួលពាក្យបណ្តឹង ធ្វើកំណត់ហេតុ និងសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធចុះពិនិត្យកន្លែងកើតហេតុប្រមូលព័ត៌មាន សម្ភារ វត្ថុតាង និងកំណត់អត្តសញ្ញាណជនសង្ស័យ
- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៣- ការិយាល័យនគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារបច្ចេកទេស និងវិទ្យាសាស្ត្រ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារបច្ចេកទេស និងវិទ្យាសាស្ត្រ
- សហការធ្វើកោសល្យវិច័យសាមញ្ញ កោសល្យវិច័យគីមីសាស្ត្រ និងជីវសាស្ត្រ
- ចាត់តាំងណែនាំអនុវត្តវិធានការជំនាញក្នុងការចុះទៅកន្លែងកើតហេតុ ដើម្បីធ្វើការវាយតម្លៃអំពីអត្ថិភាពនៃបទល្មើស ឬឧបទ្ទវហេតុផ្សេងៗ និងកត់ត្រាហេតុការណ៍ដែលកើតឡើង
- អនុវត្តវិធានការជំនាញក្នុងការរៀបចំ កសាង គ្រប់គ្រងសលាកប័ត្រជនសង្ស័យដែលបានឃាត់ខ្លួនបញ្ចូលទិន្នន័យក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- សហការប្រើប្រាស់វិធីសាស្ត្រជំនាញធ្វើកោសល្យវិច័យដើម្បីកំណត់អត្តសញ្ញាណ ប្រភពនៃបទល្មើសនានា
- កសាង គ្រប់គ្រងប័ណ្ណសារ និងរក្សាទុកទិន្នន័យគំរូប្រៀបធៀប ដើម្បីបម្រើការងារជំនាញស្រាវជ្រាវស៊ើបអង្កេត
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ឃ- ផែនការងារនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច**

**ការិយាល័យនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារប្រឆាំងបទល្មើសសេដ្ឋកិច្ច ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារប្រឆាំងបទល្មើសសេដ្ឋកិច្ច
- សហការជាមួយសមត្ថកិច្ចជំនាញពាក់ព័ន្ធលើការងារមានជាអាទិ៍ ៖
  + ចាត់វិធានការជំនាញបង្ការ និងបង្ក្រាបវិច្ឆេទកម្មសេដ្ឋកិច្ច ការស្តុកទំនិញខុសច្បាប់ ការផលិតការធ្វើចរាចរទំនិញក្លែងក្លាយ និងទំនិញហួសរយៈពេលប្រើ
  + ចាត់វិធានការបង្ការ និងបង្ក្រាបបទល្មើសសារពើពន្ធគ្រប់ប្រភេទ និងបទល្មើសក្នុងការលក់ ការផ្សាយថ្លៃទំនិញ ការផ្សាយបញ្ឆោតបន្លំ

+ ស្វែងរកមុខសញ្ញាល្មើសសារពើពន្ធ ដែលរូបវន្តបុគ្គល នីតិបុគ្គលនានាកំពុងធ្វើ ពាណិជ្ជកម្ម អាជីវកម្ម និងផលិតកម្ម ដើម្បីមានវិធានការ

+ តាមដានស្រាវជ្រាវស៊ើបអង្កេតលើរូបវន្តបុគ្គល នីតិបុគ្គលដែលនាំចូល ផលិត ធ្វើចរាចរនៅលើទីផ្សារនូវផលិតផលក្លែងបន្លំម៉ាក សម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ ដើម្បីមានវិធានការ

+ អនុវត្តវិធានការស្រាវជ្រាវស៊ើបអង្កេតលើទីតាំងផលិតកម្មគ្មានច្បាប់អនុញ្ញាត ឬកំពុងរំលោភច្បាប់ ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី

+ តាមដានស៊ើបអង្កេតទីតាំងអាជីវកម្ម ផលិតកម្ម និងចុះត្រួតពិនិត្យការបំពុលបរិស្ថាន

- អនុវត្តវិធានការជំនាញក្នុងការងារប្រយុទ្ធប្រឆាំងបទល្មើសអាជីវកម្ម សេវាកម្ម ផលិតកម្ម
- ធ្វើបច្ចុប្បន្នភាពទិន្នន័យព័ត៌មានរបស់អាជីវកម្ម សេវាកម្ម និងផលិតកម្មស្របច្បាប់ និងមិនស្របច្បាប់ ដើម្បីបម្រើការងារជំនាញស្រាវជ្រាវស៊ើបអង្កេត និងគ្រប់គ្រង
- អនុវត្តវិធានការជំនាញស្រាវជ្រាវប្រមូលព័ត៌មាន និងត្រួតពិនិត្យតម្លៃទំនិញនៅលើទីផ្សារ វិភាគវាយតម្លៃរកមូលហេតុបាតុភាពអវិជ្ជមានដែលប៉ះពាល់ដល់ស្ថិរភាពតម្លៃទំនិញលើទីផ្សារ
- ស្រាវជ្រាវ បង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពធ្វើសន្និធិទំនិញខុសច្បាប់ ការផលិត ការធ្វើចរាចរទំនិញលើទីផ្សារមានបរិមាណមិនត្រឹមត្រូវតាមស្តង់ដារ និងមាត្រសាស្ត្រ ទំនិញខូចគុណភាព ឬទំនិញហាមឃាត់ និងការក្លែងបន្លំគុណភាព
- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ង- ផែនការងារប្រឆាំងគ្រឿងញៀន**

**ការិយាល័យប្រឆាំងគ្រឿងញៀន** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារប្រឆាំងគ្រឿងញៀន ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើគោលការណ៍ ផែនការ និងវិធានការលើការងារប្រឆាំងគ្រឿងញៀន
- ចាត់វិធានការជំនាញបង្ការ និងបង្ក្រាបការប្រើប្រាស់ ការដឹកជញ្ជូន ការធ្វើជំនួញគ្រឿងញៀនគ្រប់ប្រភេទ
- ស្រាវជ្រាវតាមដានបុគ្គល យានជំនិះ ទីកន្លែងគោលដៅ និងប្រមូលព័ត៌មានពាក់ព័ន្ធសកម្មភាពអត្តសញ្ញាណជនសង្ស័យ ដើម្បីបម្រើការងារជំនាញ
- ស្រាវជ្រាវស្វែងរកច្រកផ្លូវធ្វើសកម្មភាព និងសមាសភាពក្រុមឧក្រិដ្ឋជនគ្រឿងញៀនមានការចាត់តាំងជាប្រព័ន្ធជួញដូរដឹកជញ្ជូន និងផលិតគ្រឿងញៀន
- សហការជាមួយអង្គភាពពាក់ព័ន្ធប្រមូលព័ត៌មានអំពីសកម្មភាពជំនួញសារធាតុញៀន សារធាតុគីមីផ្សំហាមឃាត់ និងការផលិតកែច្នៃគ្រឿងញៀនខុសច្បាប់ ការដាំដុះរុក្ខជាតិញៀន ការជួញដូរ ការចរាចរ ការដឹកជញ្ជូន ការរក្សាទុក ការស្តុកទុកគ្រឿងញៀនខុសច្បាប់

- ធ្វើបញ្ជីកំណត់មុខសញ្ញាប្រព្រឹត្តបទល្មើសគ្រឿងញៀនគ្រប់ប្រភេទ គោលដៅប្រឈមខ្ពស់ និងបណ្ដាច្រកព្រំដែនដឹកជញ្ជូនឆ្លងកាត់
- សិក្សាល្បិចកលការលាក់បំពួន ការដឹកជញ្ជូន និងសហការត្រួតពិនិត្យស្វែងរកការនាំចេញ នាំចូល ដឹកជញ្ជូន ការផលិតស្តុកទុកសារធាតុញៀន សារធាតុគីមីផ្សំហាមឃាត់ ឱសថមានផ្ទុកសារធាតុញៀនដែលច្បាប់កំណត់ និងការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ទៅជាការផលិតគ្រឿងញៀនខុសច្បាប់
- ធ្វើជំរឿន និងគ្រប់គ្រងជនរងគ្រោះដោយគ្រឿងញៀន ស្រាវជ្រាវស្វែងរកអ្នកញៀនគ្រឿងញៀននៅតាមលំនៅដ្ឋាន អង្គភាពប្រមូលផ្ដុំ មណ្ឌលស្ដារនីតិសម្បទា និងចូលរួមជាមួយអាណាព្យាបាលធ្វើការអប់រំឱ្យទៅមណ្ឌលសុខភាពឬមណ្ឌលអប់រំព្យាបាលតាមច្បាប់
- បែងចែកប្រភេទអ្នករងគ្រោះដោយការប្រើប្រាស់គ្រឿងញៀនតាមប្រភេទគ្រឿងញៀន ប្រភេទអាយុ មុខរបរ និងរូបភាពការប្រើប្រាស់ ដើម្បីលើកសំណើគោលការណ៍បន្សាប និងព្យាបាល
- ចងក្រងបញ្ជី និងគ្រប់គ្រងគោលដៅប្រឈមងាយរងគ្រោះមានជាអាទិ៍ ៖ គ្រឹះស្ថានសិក្សា ក្លឹបរាត្រី ទីតាំងប្រកបអាជីវកម្ម ខារ៉ាអូខេ វង្គសាល បើកល្បែង ផ្ទះជួល ផ្ទះសំណាក់ សណ្ឋាគារ ខុនដូ តំបន់មិនរៀបរយដែលងាយកើតបទល្មើស
- ស្រាវជ្រាវ និងគ្រប់គ្រងគោលដៅអាជីវកម្មរូបិយប័ណ្ណ រូបិយវត្ថុ គ្រឹះស្ថានឥណទាន ស្ថាប័នហិរញ្ញវត្ថុ បនល្បែង ក្រុមហ៊ុនវដ្ត ឯកជនដែលមាន ឬគ្មានច្បាប់អនុញ្ញាតដើម្បីស្វែងរកអត្តសញ្ញាណម្ចាស់សាច់ប្រាក់ ប្រភពរូបិយប័ណ្ណ រូបិយវត្ថុ និងការចរាចរសាច់ប្រាក់ ការផ្ទេរ ការជួញដូរចលន អចលនទ្រព្យដែលជាការលាងលុយកខ្វក់មកជាលុយស្របច្បាប់
- ដំណើរការស្រាវជ្រាវល្បិចកល សកម្មភាពរបស់ឧក្រិដ្ឋជនគ្រឿងញៀនក្នុងការសម្អាតប្រាក់ដែលបានមកពីផលជំនួញគ្រឿងញៀនខុសច្បាប់
- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ច- ផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រ**

**ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- ចាត់វិធានការជំនាញបង្ការ និងបង្ក្រាបសកម្មភាពរំលោភលើរូបរាងកាយបុគ្គល និងសេចក្តីថ្លៃថ្នូរ
- អនុវត្តគោលការណ៍ វិធីសាស្រ្តបង្ការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរ ការរត់ពន្ធមនុស្ស អំពើហិង្សាក្នុងគ្រួសារ ការប្រទូស្តកេរខ្មាស់ និងរំលោភសេពសន្ថវៈលើនីតិជន អនីតិជន និងកាមសាស្ត្រលើកុមារ
- ចាប់ខ្លួនចារី សហចារី ដកហូតសម្ភារ វត្ថុតាងពាក់ព័ន្ធ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី

- ស៊ើបអង្កេតរាល់ករណី និងពាក្យបណ្ដឹងដែលពាក់ព័ន្ធអំពើជួញដូរ អាជីវកម្មផ្លូវភេទ អំពើកាមសាស្ត្រ និងអំពើកេងប្រវ័ញ្ចគ្រប់រូបភាពលើកុមារ
- អនុវត្តវិធានការជំនាញស្រាវជ្រាវស៊ើបអង្កេតបណ្ដាគេហទំព័រ និងគោលដៅបញ្ចាំងវីដេអូអាសអាភាស និងទីតាំងផលិតចែកចាយរូបភាពអាសអាភាស
- ស៊ើបអង្កេតរាល់ករណី និងពាក្យបណ្ដឹងពាក់ព័ន្ធអំពើហិង្សាក្នុងគ្រួសារដែលប៉ះពាល់ដល់រូបរាងកាយ ការធ្វើទារុណកម្ម និងអំពើប្រទូស្តកេរខ្មាស់ រំលោភសេពសន្ថវៈលើនីតិជន និងអនីតិជន
- សហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីធ្វើកោសល្យវិច័យស្លាកស្នាម របួសដោយអំពើរំលោភសេពសន្ថវៈលើនីតិជន និងអនីតិជន
- រៀបចំបណ្ដាញទូរស័ព្ទពិសេស វិទ្យុទាក់ទង ចាត់កម្លាំងប្រចាំការ ២៤ម៉ោង សម្រាប់ទទួលព័ត៌មានអំពីហេតុការណ៍ដែលកើតឡើង
- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ធ- ផែនការងារសន្តិសុខ**

**១- ការិយាល័យសន្តិសុខផ្ទៃក្នុង** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារសន្តិសុខផ្ទៃក្នុង ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារសន្តិសុខផ្ទៃក្នុង
- ប្រមូល និងវិភាគព័ត៌មានគ្រប់ប្រភេទដែលពាក់ព័ន្ធដល់សន្តិសុខជាតិ
- ស៊ើបបញ្ជាក់ព័ត៌មាន ចងក្រងទុកជាឯកសារជាតិ និងឯកសារជំនាញ
- ប្រមូលព័ត៌មានសន្តិសុខផ្ទៃក្នុង ដើម្បីស៊ើបបញ្ជាក់ប្រមូលភស្តុតាង បម្រើកិច្ចប្រតិបត្តិការជំនាញតាមច្បាប់កំណត់
- សហការជាមួយអង្គភាពពាក់ព័ន្ធស៊ើបបញ្ជាក់ព័ត៌មាន ដើម្បីបង្ការ និងទប់ស្កាត់សកម្មភាពធ្វើឲ្យបែកការសម្ងាត់រដ្ឋ
- សហការជាមួយស្ថាប័នពាក់ព័ន្ធលើវិធានការការពារសន្តិសុខ សុវត្ថិភាពជូនឥស្សរជន និងគោលដៅសំខាន់ៗ
- សហការជាមួយអង្គភាពពាក់ព័ន្ធដែលមានសមត្ថកិច្ចគ្រប់គ្រងការងារសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង្ការទប់ស្កាត់រាល់សកម្មភាពបង្កអស្ថិរភាពនយោបាយ ចលាចលសង្គម
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធស្រាវជ្រាវបង្ការ ទប់ស្កាត់ការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម ការបង្កើតតំបន់អប្បគមន៍ កសាងកម្លាំងប្រដាប់អាវុធខុសច្បាប់ កុប្បកម្ម និងអំពើទុច្ចរិតនានា
- ចាត់វិធានការស្រាវជ្រាវ និងតាមដានសកម្មភាពការលួចជ្រៀតចូលដោយប្រើឈ្មោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនានា ធ្វើសកម្មភាពខុសច្បាប់ និងការនាំពលករខ្មែរចេញធ្វើការក្រៅប្រទេស
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធស្រាវជ្រាវប្រមូលព័ត៌មានពាក់ព័ន្ធសកម្មភាពខុសច្បាប់ក្នុងវិស័យអប់រំ វប្បធម៌ សិល្បៈ ប្រព័ន្ធឃោសនា ភេរវកម្ម ផលិតកម្ម ផ្សព្វផ្សាយ និងការចែកចាយព័ត៌មានតាមគ្រប់មធ្យោបាយ

- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

២- **ការិយាល័យប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន
- ប្រមូលព័ត៌មាន និងស៊ើបបញ្ជាក់រាល់ព័ត៌មានពាក់ព័ន្ធអំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន បទល្មើសប្រឆាំងនឹងសន្តិសុខជាតិ
- ស្វែងរកចាប់ខ្លួនមុខសញ្ញាភេរវជន និងកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី
- ប្រមូលព័ត៌មានពីគ្រប់មជ្ឈដ្ឋាន ដើម្បីពិនិត្យវិភាគវាយតម្លៃអំពីឧបាយកល និងសកម្មភាពភេរវកម្ម
- ស្រាវជ្រាវបង្ការទប់ស្កាត់បាតុភាពទំនាស់ក្នុងសហគមន៍ជាតិសាសន៍ សាសនា ការបង្កើតតំបន់ អប្បគមន៍ កសាងកម្លាំងប្រដាប់អាវុធខុសច្បាប់
- ចាត់វិធានការស្រាវជ្រាវក្រុមភេរវករ និងបណ្ដាញអង្គការភេរវកម្មដែលមានការចាត់តាំង
- ចងក្រង គ្រប់គ្រងបញ្ជីខ្មៅមុខសញ្ញាភេរវករ និងអង្គការភេរវកម្ម
- ស្រាវជ្រាវ បង្ការទប់ស្កាត់សកម្មភាពប្រមូលផ្ដុំមនុស្សខុសច្បាប់មានជាអាទិ៍ ៖ បាតុកម្ម កូដកម្ម កុប្បកម្ម វិទ្ធង្សនា និងការបង្កចលាចលផ្សេងៗ
- ចាត់វិធានការស្រាវជ្រាវចងក្រងបញ្ជីអង្គការ ក្រុមហ៊ុន និងមុខសញ្ញាពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- ស្រាវជ្រាវរចនាសម្ព័ន្ធ និងដំឡើងបញ្ជីអង្គការមុខសញ្ញាសង្ស័យឧក្រិដ្ឋកម្មឆ្លងដែន
- ចងក្រងដំឡើងបញ្ជីសហគមន៍ទៅតាមប្រភេទ និងនិកាយសាសនានីមួយៗ
- ស្រាវជ្រាវមុខសញ្ញា និងសមាសភាពដែលយកសហគមន៍ និងសាសនាធ្វើសកម្មភាពក្រោមរូបភាពផ្សេងៗ ដើម្បីញុះញង់បង្កចលាចលអស្ថិរភាពសង្គម
- ស្រាវជ្រាវអនុវត្តដីកា និងការពារជនសង្ស័យដែលត្រូវឃុំខ្លួនបណ្ដោះអាសន្នតាមនីតិវិធី
- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

៣- **ការិយាល័យគ្រប់គ្រងសន្តិសុខឯកជន** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារគ្រប់គ្រងសន្តិសុខឯកជន ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារគ្រប់គ្រងសន្តិសុខឯកជន
- ត្រួតពិនិត្យសំណុំបែបបទការស្នើសុំច្បាប់អនុញ្ញាតជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនរបស់សហគ្រាស គ្រឹះស្ថាននានា

- គ្រប់គ្រងទិន្នន័យ សំណុំបែបបទ និងបញ្ជីឈ្មោះភ្នាក់ងារសន្តិសុខឯកជនតាមប្រព័ន្ធព័ត៌មានវិទ្យា
- លើកផែនការបណ្តុះបណ្តាលជំនាញឯកទេស ដល់ភ្នាក់ងារសន្តិសុខឯកជន
- ប្រមូលព័ត៌មានតាមបណ្តាសហគ្រាស គ្រឹះស្ថាននានាដែលប្រើសេវាសន្តិសុខឯកជន
- ត្រួតពិនិត្យណែនាំសហគ្រាស គ្រឹះស្ថាននានា ដែលប្រើសេវាសន្តិសុខឯកជនផ្ទាល់ខ្លួនអនុវត្តតាមកិច្ចសន្យាជាមួយស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- ត្រួតពិនិត្យឧបករណ៍ សម្ភារបច្ចេកទេស មធ្យោបាយ សត្វសម្រាប់បម្រើសកម្មភាពការពារសន្តិសុខ
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធអន្តរាគមន៍ និងស៊ើបអង្កេតរាល់បាតុភាព ឬឧបទ្ទវហេតុដែលកើតឡើងនៅតាមគោលដៅសហគ្រាស គ្រឹះស្ថាននានាដែលប្រើសេវាសន្តិសុខផ្ទាល់ខ្លួន
- សហការជាមួយសហគ្រាស គ្រឹះស្ថាននានាដែលប្រើសេវាសន្តិសុខឯកជនផ្ទាល់ខ្លួន ការពារទីតាំង និងការពារការដឹកជញ្ជូនរូបិយប័ណ្ណ ទ្រព្យសម្បត្តិ និងវត្ថុមានតម្លៃស្របច្បាប់
- លើកយោបល់សុំគោលការណ៍លុបចោល ឬផ្អាកសកម្មភាពជាបណ្តោះអាសន្ន ឬដកហូតលិខិតអនុញ្ញាត ឬផ្តល់ឡើងវិញចំពោះសហគ្រាស គ្រឹះស្ថាន ប្រើសេវាសន្តិសុខផ្ទាល់ខ្លួនដែលធ្វើសកម្មភាពផ្ទុយពីលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

៤- **ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារប្រឆាំងបទល្មើសបច្ចេកវិទ្យា ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារប្រឆាំងបទល្មើសបច្ចេកវិទ្យា
- សហការជាមួយសាខាចែកចាយសេវាទូរគមនាគមន៍គ្រប់ប្រភេទ ដើម្បីត្រួតពិនិត្យការចុះបញ្ជី ភ្ជាប់ប្រើប្រាស់សេវាទូរគមនាគមន៍ និងបច្ចេកវិទ្យាតាមការកំណត់
- សហការជាមួយស្ថាប័នរដ្ឋ និងឯកជន ដែលធ្វើអាជីវកម្មសេវាហិរញ្ញវត្ថុ ដើម្បីស្រាវជ្រាវស៊ើបអង្កេតប្រមូលភស្តុតាង និងបង្ក្រាបបទល្មើសហិរញ្ញវត្ថុតាមប្រព័ន្ធបច្ចេកវិទ្យា
- តាមដានប្រមូលព័ត៌មានលើបណ្តាញសង្គម និងអ៊ីនធឺណែត វិភាគវាយតម្លៃសភាពការណ៍បង្កអសន្តិសុខ និងអស្ថិរភាពសង្គម
- ស្រាវជ្រាវស៊ើបបញ្ជាក់ ប្រមូលភស្តុតាង និងសាវតារបស់គណនីមុខសញ្ញាប្រព្រឹត្តបទល្មើសតាមបណ្តាញសង្គមបច្ចេកវិទ្យា ដើម្បីកសាងសំណុំរឿងតាមនីតិវិធី
- ធ្វើរបាយការណ៍ស្រាវជ្រាវករណី និងប្រមូល គ្រប់គ្រងវត្ថុតាងជូននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ដើម្បីផ្តល់ការណែនាំជំនាញបច្ចេកទេស និងការធ្វើកោសល្យវិច័យបច្ចេកវិទ្យាតាមនីតិវិធី
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៥- ការិយាល័យអង្គរក្ស** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារអង្គរក្ស ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារអង្គរក្ស
- ការពារសុវត្ថិភាពថ្វាយព្រះមហាក្សត្រ ជូនថ្នាក់ដឹកនាំជាតិ និងអន្តរជាតិក្នុងវង្វង់សមត្ថកិច្ចទទួលខុសត្រូវ
- សហការជាមួយកម្លាំងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធានាការពារសន្តិសុខសុវត្ថិភាពជូនថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ ក្នុងពេលបំពេញបេសកកម្ម
- ស្រាវជ្រាវ ក្តាប់សភាពការណ៍ដើម្បីកសាងផែនការការពារ និងបង្ការទប់ស្កាត់
- ប្រចាំការ២៤ម៉ោង ត្រៀមអន្តរាគមន៍ទប់ស្កាត់រាល់ឧបទ្ទវហេតុដែលកើតឡើងនៅតាមគោលដៅដែលទទួលខុសត្រូវ
- រក្សារបៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈនៅជុំវិញបរិវេណគោលដៅប្រារព្ធពិធីផ្សេងៗ
- សហការជាមួយស្ថាប័នពាក់ព័ន្ធចាប់ខ្លួន ឃាត់ខ្លួនជនល្មើស រឺជនសង្ស័យដែលមានបំណងធ្វើសកម្មភាពជាក់ស្តែង
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ជ- ផែនការងារនគរបាលសណ្តាប់ធ្នាប់**

**១- ការិយាល័យនគរបាលសណ្តាប់ធ្នាប់** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារសណ្តាប់ធ្នាប់ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារសណ្តាប់ធ្នាប់
- ចាត់វិធានការជំនាញក្នុងការរៀបចំសណ្តាប់ធ្នាប់នៅតាមទីកន្លែងសាធារណៈ
- ល្បាត និងត្រួតពិនិត្យអំពើល្មើសនឹងបទប្បញ្ញត្តិសណ្តាប់ធ្នាប់សាធារណៈ
- ណែនាំ និងពិន័យចំពោះជនដែលប្រព្រឹត្តល្មើសបទប្បញ្ញត្តិសណ្តាប់ធ្នាប់សាធារណៈ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យនគរបាលទេសចរណ៍** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារទេសចរណ៍ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារទេសចរណ៍
- ចាត់វិធានការជំនាញបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពប៉ះពាល់ដល់សុវត្ថិភាពរបស់ទេសចរ
- ស្រាវជ្រាវ ស៊ើបអង្កេត និងដោះស្រាយរាល់បទល្មើសច្បាប់ផ្សេងៗ ដែលប៉ះពាល់ដល់រូបរាងកាយ អាយុជីវិត ទ្រព្យសម្បត្តិ និងកិត្តិយសរបស់ទេសចរ
- ពិនិត្យ និងដោះស្រាយពាក្យបណ្តឹងដែលពាក់ព័ន្ធដល់ទេសចរជាតិ និងអន្តរជាតិ

- ធ្វើកំណត់ហេតុរល់បណ្តឹងអំពីការបាត់ខ្លួន ការប៉ះពាល់រូបរាងកាយ ទ្រព្យសម្បត្តិ ផលប្រយោជន៍ និងកិត្តិយសរបស់ទេសចរ
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ អនុវត្តការចាប់ខ្លួន ឃាត់ខ្លួនជនល្មើស ក្នុងករណីបទល្មើសជាក់ស្តែងតាមនីតិវិធី
- ចាត់វិធានការជំនាញថែរក្សាការពារសន្តិសុខ សុវត្ថិភាពដល់ទេសចរជាតិ និងអន្តរជាតិដែលមកកម្សាន្ត ឬទស្សនកិច្ច
- រក្សារបៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈនៅបរិវេណរមណីយដ្ឋានវប្បធម៌ធម្មជាតិ និងរមណីយដ្ឋានផ្សេងៗទៀត
- បោះទីតាំងប្រចាំការការពារ និងល្បាតចល័តតាមគោលដៅដែលមានការប្រមូលផ្តុំទេសចរ ដើម្បីផ្តល់ ទទួលព័ត៌មាន និងអន្តរាគមន៍ទាន់ពេលវេលា
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

៣- **ការិយាល័យនគរបាលការពារបេតិកភណ្ឌ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារការពារបេតិកភណ្ឌ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារការពារបេតិកភណ្ឌ
- ចាត់វិធានការជំនាញការពារទ្រព្យសម្បត្តិវប្បធម៌បេតិកភណ្ឌប្រវត្តិសាស្ត្រជាតិ ក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ
- ឃោសនាផ្សព្វផ្សាយណែនាំអប់រំសង្គមដើម្បីចូលរួមថែរក្សាការពារបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិ
- ចុះបញ្ជីប័ណ្ណសារបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិក្នុងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីបម្រើការងារគ្រប់គ្រងទុកដាក់ និងថែរក្សាការពារ
- សហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ សមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋ ដើម្បីរួមចំណែកការពារបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិ
- ចាត់វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសបំផ្លិចបំផ្លាញ លួចលាក់ ប្លន់ ទិញ លក់ ជីករុករក ដឹកជញ្ជូនបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ឈ- ផែនការងារនគរបាលចរាចរណ៍**

១- **ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារចរាចរណ៍ផ្លូវគោក ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារចរាចរណ៍ផ្លូវគោក ផ្លូវដែក
- ត្រួតពិនិត្យ ណែនាំ និងពិន័យម្ចាស់យានយន្ត អ្នកបើកបរដែលល្មើសច្បាប់ចរាចរណ៍ផ្លូវគោក ផ្លូវដែក

- ចុះអង្កេត ស្រាវជ្រាវប្រមូលភស្តុតាងករណីរំលោភច្បាប់ចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី
- សហការត្រួតពិនិត្យបច្ចេកទេសនៅតាមយានដ្ឋានជួសជុល កែច្នៃ ដំឡើងយានយន្តគ្រប់ប្រភេទតាមការកំណត់
- សហការឃោសនាផ្សព្វផ្សាយអប់រំណែនាំប្រជាពលរដ្ឋឲ្យយល់ដឹង និងគោរពអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ផ្លូវដែក
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យនគរបាលចរាចរណ៍ផ្លូវទឹក** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារចរាចរណ៍ផ្លូវទឹក ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារចរាចរណ៍ផ្លូវទឹក
- ត្រួតពិនិត្យ ណែនាំ និងពិន័យម្ចាស់ជលយាន បរិបាលដែលល្មើសច្បាប់ចរាចរណ៍ផ្លូវទឹក
- ចុះអង្កេតស្រាវជ្រាវប្រមូលភស្តុតាងករណីរំលោភបទដ្ឋានសុវត្ថិភាពចរាចរណ៍ផ្លូវទឹក ព្រមទាំងកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី
- សហការត្រួតពិនិត្យបច្ចេកទេសនៅតាមយានដ្ឋានជួសជុល កែច្នៃ ដំឡើងជលយានគ្រប់ប្រភេទតាមការកំណត់
- សហការឃោសនាផ្សព្វផ្សាយអប់រំណែនាំប្រជាពលរដ្ឋឲ្យយល់ដឹង និងគោរពអនុវត្តបទដ្ឋានសុវត្ថិភាពចរាចរណ៍ផ្លូវទឹក
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៣- ផែនការងារគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងអគ្គិភ័យ**

**១- ការិយាល័យនគរបាលបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារបង្ការពន្លត់អគ្គិភ័យ និងសង្គ្រោះ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារបង្ការពន្លត់អគ្គិភ័យ និងសង្គ្រោះ
- ចាត់វិធានការជំនាញបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ
- ផ្សព្វផ្សាយអំពីវិធានការបង្ការ ទប់ស្កាត់គ្រោះមហន្តរាយដែលកើតឡើងដោយអគ្គិភ័យ ដោយធម្មជាតិ និងមនុស្ស
- ផ្សព្វផ្សាយណែនាំអប់រំដល់ប្រជាពលរដ្ឋ សហគមន៍អំពីការងារបង្ការ និងការពន្លត់អគ្គិភ័យ
- គ្រប់គ្រងការនាំចូល ស្តុក ចែកចាយ ដឹកជញ្ជូន និងការប្រើប្រាស់ឧបករណ៍ សម្ភារបរិក្ខារបម្រើការងារបង្ការអគ្គិភ័យតាមច្បាប់
- ប្រមូល កត់ត្រា គ្រប់គ្រងទិន្នន័យ និងដំឡើងផែនទីភូមិសាស្ត្រ វិភាគអំពីផលប៉ះពាល់ ដើម្បីមានវិធានការបង្ការ និងពន្លត់អគ្គិភ័យ

- គ្រប់គ្រងថែរក្សារថយន្ត ឧបករណ៍សម្ភារបរិក្ខារ ប្លង់ប្រភពទឹក ប្លង់យុទ្ធសាស្ត្រ និងប្រព័ន្ធបង្ការពន្លត់អគ្គិភ័យ
- លើកគម្រោងជួសជុលថែទាំ កែច្នៃមធ្យោបាយសម្ភារបច្ចេកទេសពន្លត់អគ្គិភ័យ និងសង្គ្រោះ
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែង ចាត់វិធានការបន្ទាន់ជួយសង្គ្រោះជីវិតមនុស្ស ទ្រព្យសម្បត្តិ និងពន្លត់អគ្គិភ័យ
- អនុវត្តវិធានការជំនាញសង្គ្រោះបន្ទាន់ក្នុងការដឹកជញ្ជូន ជម្លៀសជនរងគ្រោះដោយអគ្គិភ័យ និងឧបទ្ទវហេតុផ្សេងៗ ទៅរកទីកន្លែងសុវត្ថិភាព ឬបញ្ជូនទៅមន្ទីរពេទ្យ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងជាតិពុល** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងជាតិពុល ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារគ្រប់គ្រងអាវុធគ្រឿងផ្ទុះ ជាតិពុល
- ចុះបញ្ជីគ្រប់គ្រងស្ថិតិអាវុធ គ្រឿងផ្ទុះ និងជាតិពុលតាមច្បាប់
- ត្រួតពិនិត្យ និងណែនាំបច្ចេកទេសដល់បណ្ដាក្រុមហ៊ុនអាជីវកម្ម ផលិតកម្មអង្គភាពនានាដែលប្រើប្រាស់សារធាតុងាយឆេះ
- គ្រប់គ្រងការនាំចូល ស្ដុកទុក បែងចែក ដឹកជញ្ជូន និងការប្រើប្រាស់សារធាតុងាយឆេះ ងាយផ្ទុះឆេះតាមច្បាប់
- តាមដានការប្រើប្រាស់គ្រឿងផ្ទុះនៅតាមទីតាំងការដ្ឋាននានាក្នុងវង្វង់សមត្ថកិច្ចទទួលខុសត្រូវ
- ចាត់វិធានការជំនាញស្រាវជ្រាវ និងដកហូតអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទដែលខុសច្បាប់
- សហការជាមួយសមត្ថកិច្ចជំនាញពាក់ព័ន្ធស្រាវជ្រាវបង្ការទប់ស្កាត់ និងបង្រ្កាបបទល្មើសច្បាប់គ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ
- អនុវត្តវិធានការជំនាញស្រាវជ្រាវស៊ើបអង្កេតប្រមូលភស្តុតាង ឃាត់ខ្លួនជនសង្ស័យ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី
- គ្រប់គ្រងការប្រកបមុខរបរងាយប៉ះពាល់ដល់សង្គម សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ ការទិញលក់ ដឹកជញ្ជូន នាំចូល ចែកចាយ និងការប្រើប្រាស់អាស៊ីដខ្លាំងតាមច្បាប់កំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ជ- ផែនការងារអន្តោប្រវេសន៍**

**១- ការិយាល័យគ្រប់គ្រងជនបរទេស** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារគ្រប់គ្រងជនបរទេស ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារគ្រប់គ្រងជនបរទេស
- គ្រប់គ្រងស្ថិតិ ការស្នាក់នៅ ការប្រកបមុខរបរជនបរទេសមិនមែនអន្តោប្រវេសន្ត ជនបរទេសអន្តោប្រវេសន្ត ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន ជនបរទេសសុំសិទ្ធិជ្រកកោន ជនភៀសខ្លួន និងជនជាតិខ្មែរធ្វើមាតុភូមិនិវត្តន៍តាមច្បាប់ជាតិ និងអន្តរជាតិ
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងការគ្រប់គ្រងការស្នាក់នៅ និងការប្រកបមុខរបររបស់ជនបរទេស
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារស៊ើបអង្កេត និងអនុវត្តនីតិវិធីចំពោះបទល្មើសបង្កឡើងដោយជនបរទេស និងជនពាក់ព័ន្ធ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការបង្ការទប់ស្កាត់ស្រាវជ្រាវ និងបង្ក្រាបបទល្មើសប៉ះពាល់ដល់សន្តិសុខជាតិ និងសុវត្ថិភាពសង្គម ដែលប្រព្រឹត្តដោយជនបរទេស និងជនពាក់ព័ន្ធ
- ប្រមូលព័ត៌មានដែលពាក់ព័ន្ធសន្តិសុខជាតិ និងសុវត្ថិភាពសង្គម ដែលបង្កឡើងដោយជនបរទេស និងជនពាក់ព័ន្ធ
- សហការជាមួយស្ថាប័នតុលាការដើម្បីបើកការស៊ើបអង្កេត និងអនុវត្តនីតិវិធីច្បាប់រាល់បទល្មើសប៉ះពាល់ដល់សន្តិសុខជាតិ និងសុវត្ថិភាពសង្គម ដែលប្រព្រឹត្តដោយជនបរទេស និងជនពាក់ព័ន្ធ
- ប្រមូល និងគ្រប់គ្រងទិន្នន័យជនបរទេសដែលជាប់ពន្ធនាគារ និងជនបរទេសដែលជួបគ្រោះថ្នាក់ផ្សេងៗ ក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ
- ពិនិត្យ ស៊ើបបញ្ជាក់អំពីអត្តសញ្ញាណ និងសាវតារជនបរទេសដែលស្នើសុំរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ឋ- ផែនការងារអត្តសញ្ញាណកម្ម**

**១- ការិយាល័យគ្រប់គ្រងការស្នាក់នៅ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើគ្រប់គ្រងការស្នាក់នៅរបស់ប្រជាពលរដ្ឋ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារគ្រប់គ្រងការស្នាក់នៅរបស់ប្រជាពលរដ្ឋ
- គ្រប់គ្រងការប្រែប្រួល និងធ្វើបច្ចុប្បន្នភាពបញ្ជីស្នាក់នៅរបស់ប្រជាពលរដ្ឋ
- ទទួល និងបែងចែកឯកសារសម្គាល់ការស្នាក់នៅ ឯកសារសម្គាល់គ្រួសារ និងឯកសារផ្លាស់ប្តូរទីលំនៅដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ប្រមូលគ្រប់គ្រង និងវិភាគទិន្នន័យស្តីពីការស្នាក់នៅរបស់ប្រជាពលរដ្ឋ ពីអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ

- ចាត់វិធានការ បង្ការ ទប់ស្កាត់ និងស្រាវជ្រាវភាពមិនប្រក្រតីក្នុងការចុះបញ្ជីស្នាក់នៅរបស់ប្រជាពលរដ្ឋ
- ផ្សព្វផ្សាយអប់រំ ប្រជាពលរដ្ឋអំពីបែបបទនីតិវិធី និងសារៈសំខាន់នៃការចុះបញ្ជីស្នាក់នៅរបស់ប្រជាពលរដ្ឋ
- ស្រាវជ្រាវស្វែងរកមនុស្សបាត់ខ្លួន
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការស្រង់ស្ថិតិផ្សេងទៀត
- គ្រប់គ្រង ថែរក្សាទិន្នន័យចុះបញ្ជីការស្នាក់នៅរបស់ប្រជាពលរដ្ឋតាមប្រព័ន្ធព័ត៌មានវិទ្យា
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ចាត់វិធានការស្រង់ និងធ្វើបច្ចុប្បន្នភាពទិន្នន័យប្រជាពលរដ្ឋដែលត្រូវផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- តាមដានជំរុញ និងអនុវត្តការងារផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ផ្សព្វផ្សាយអប់រំជូនប្រជាពលរដ្ឋអំពីបែបបទនីតិវិធី និងសារៈសំខាន់នៃអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- គ្រប់គ្រងថែរក្សាទិន្នន័យអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរតាមប្រព័ន្ធព័ត៌មានវិទ្យា
- គ្រប់គ្រងថែរក្សា ឧបករណ៍សម្ភារបច្ចេកទេសបម្រើឲ្យការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ចាត់វិធានការ បង្ការទប់ស្កាត់ស្រាវជ្រាវភាពមិនប្រក្រតី ទាក់ទងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ឱ- ផែនការងារភស្តុភារ និងហិរញ្ញវត្ថុ**

**១- ការិយាល័យភស្តុភារ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារភស្តុភារ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារភស្តុភារ
- លើកគម្រោងផែនការ និងបើកផ្តល់សម្ភារ សំលៀកបំពាក់ ឯកសណ្ឋាន ស្បៀងអាហារ ប្រេងឥន្ធនៈ និងការផ្គត់ផ្គង់ទព្វសម្ភារផ្សេងៗទៀត តាមការកំណត់របស់ក្រសួង
- លើកគម្រោង និងបើកផ្តល់សម្ភារបច្ចេកទេស បរិក្ខារសឹក គ្រឿងបន្លាស់មធ្យោបាយនានារបស់នគរបាលជាតិ
- គ្រប់គ្រង និងធ្វើសន្និធិត្រីមាស ឆមាស ឆ្នាំ នូវទ្រព្យសម្បត្តិរដ្ឋ សម្ភារប្រើប្រាស់ផ្សេងៗ របស់ស្នងការដ្ឋាន តាមការកំណត់របស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ និងអចលនទ្រព្យរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យគណនេយ្យ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារគណនេយ្យ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារគណនេយ្យ
- កសាងផែនការថវិកា និងផែនការយុទ្ធសាស្ត្រថវិការបស់ស្នងការដ្ឋាន
- លើកគម្រោង និងបើកផ្ដល់បៀវត្ស របបឧបត្ថម្ភផ្សេងៗតាមការកំណត់របស់រដ្ឋ និងការចំណាយប្រតិបត្តិការរបស់ស្នងការដ្ឋាន
- លើកគម្រោងសាងសង់ ជួសជុល ថែទាំអគារធ្វើការ ទីបញ្ជាការ ជម្រកស្នាក់នៅ លេណដ្ឋាន ដើម្បីបម្រើកិច្ចប្រតិបត្តិការ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៣- ការិយាល័យសុខាភិបាល** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារសុខាភិបាល ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារសុខាភិបាល
- ពិនិត្យសុខភាព និងបើកផ្ដល់ឱសថសម្រាប់ថែទាំព្យាបាលជម្ងឺដល់មន្ត្រីនគរបាលជាតិនៅក្រោមឱវាទស្នងការដ្ឋាន
- កសាងផែនការ វិធានការ វិធីសាស្ត្រក្នុងការងារសុខាភិបាល បម្រើដល់មន្ត្រីនគរបាលជាតិក្រោមឱវាទស្នងការដ្ឋាន
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ឃ- ផែននគរបាលការពារព្រំដែនគោក** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារការពារព្រំដែនគោក ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារការពារព្រំដែនគោក
- អនុវត្តវិធានការជំនាញក្ដាប់សភាពការណ៍ ប្រមូលព័ត៌មាន ល្បាតថែរក្សាការពារបង្គោលសីមាវត្ថុ ធាតុគោល សញ្ញាសម្គាល់ផ្សេងៗក្នុងរង្វង់សមត្ថកិច្ចទទួលខុសត្រូវ
- ប្រើប្រាស់វិធានការជំនាញ បង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែន និងបទល្មើសនៅតាមខ្សែបន្ទាត់ព្រំដែនគោក

- កសាងផែនការយាមល្បាតការពារព្រំដែន ផែនការការពារទីបញ្ជាការវរសេនាតូច ប៉ុស្តិ៍នគរបាលការពារព្រំដែនគោក និងកសាងប្រព័ន្ធការពារតាមយុទ្ធសាស្ត្រ
- សហការជាមួយរដ្ឋបាលដែនដី និងសមត្ថកិច្ចពាក់ព័ន្ធ ក្តាប់ស្ថានភាពប្រជាពលរដ្ឋ ការពារសន្តិសុខសណ្តាប់ធ្នាប់ និងសង្គ្រោះអាយុជីវិត ការពារទ្រព្យសម្បត្តិប្រជាពលរដ្ឋក្នុងគ្រោះមហន្តរាយផ្សេងៗ
- ទំនាក់ទំនងសហការជាមួយរដ្ឋបាលដែនដី និងសមត្ថកិច្ចនៃប្រទេសជិតខាង ក្នុងការដោះស្រាយបាតុភាពដែលកើតឡើងដោយថាហេតុនៅតាមតំបន់ព្រំដែនគោកតាមការកំណត់
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធអនុវត្តការចាប់ខ្លួន ឃាត់ខ្លួនពាក់ព័ន្ធបទល្មើសឆ្លងដែន និងបទល្មើសនៅតាមខ្សែបន្ទាត់ព្រំដែនគោកតាមនីតិវិធី
- សហការជាមួយរដ្ឋបាលដែនដី និងសមត្ថកិច្ចពាក់ព័ន្ធឃោសនាអប់រំប្រជាពលរដ្ឋចូលរួមអនុវត្តគោលនយោបាយការពារជាតិ ច្បាប់ បទប្បញ្ញត្តិផ្សេងៗ អំពីព្រំដែន សំដៅកសាងព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ
- គ្រប់គ្រង និងប្រើប្រាស់បណ្តាញវិទ្យុទាក់ទង ទូរសារ ទូរស័ព្ទសម្រាប់បម្រើកិច្ចប្រតិបត្តិការ
- លើកគម្រោងសាងសង់ ជួសជុលទីបញ្ជាការ ជម្រកស្នាក់នៅ សេណាដ្ឋាន និងការងារបង្កបង្កើនផល ចិញ្ចឹមសត្វ ដើម្បីរួមចំណែកលើកកម្ពស់ជីវភាពរបស់មន្ត្រីនគរបាលជាតិ
- ធ្វើការងាររដ្ឋបាល បុគ្គលិក ភស្តុភារ និងគណនេយ្យរបស់វរសេនាតូចនគរបាលការពារព្រំដែនគោកតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់ប៉ុស្តិ៍នគរបាលការពារព្រំដែនគោក
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ប្រការ៥.**

រចនាសម្ព័ន្ធរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៦.**

- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដឹកនាំដោយស្នងការចំនួន០១រូប និងមានស្នងការរងមួយចំនួនជាជំនួយការសម្រាប់ដឹកនាំផែនការងារនីមួយៗ ។ ដោយឡែក ផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រ ដឹកនាំដោយស្នងការរងជានារី
- ការិយាល័យចំណុះផែនការងារនីមួយៗដឹកនាំដោយនាយការិយាល័យចំនួន០១រូប និងមាននាយរងចំនួន០២រូប ជាជំនួយការ ។ ដោយឡែកការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន មាននាយរងការិយាល័យចំនួន០១រូប ជានារី
- វរសេនាតូចនគរបាលការពារព្រំដែនគោកនីមួយៗ ដឹកនាំដោយមេបញ្ជាការចំនួន០១រូប និងមានមេបញ្ជាការរងចំនួន០៤រូប ជាជំនួយការ ។

**ប្រការ៧.**

រចនាសម្ព័ន្ធរបស់ការិយាល័យ និងតួនាទី ភារកិច្ចរបស់ផ្នែកចំណុះការិយាល័យនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ។

**ប្រការ៨.-**

ទំនាក់ទំនងការងារ ៖

- វាំងស្នងការនគរបាលរាជធានី ខេត្ត និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាទំនាក់ទំនងណែនាំអនុវត្តគោលការណ៍ ផែនការរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ពាក់ព័ន្ធការងារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ
- វាំងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងនាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួង ជាទំនាក់ទំនងបញ្ជាដឹកនាំការងារជំនាញ
- វាំងអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ វរសេនាតូចនគរបាលការពារព្រំដែនគោក និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ជាទំនាក់ទំនងគ្រប់គ្រងបញ្ជាដឹកនាំការងារជំនាញ ។

**ប្រការ៩.-**

ប្រកាសលេខ ១៩១២ ប្រ.ក ចុះថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៨ ស្ដីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវទុកជានិរាករណ៍ និងជំនួសដោយប្រកាសនេះ ។

**ប្រការ១០.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកស្តុភារ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល៖</u>

- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេចឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ១០*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធនៃប្រកាសលេខ [illegible] ប្រ.ក
ចុះថ្ងៃ [illegible] ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៨
ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាន
នគរបាលរាជធានី ខេត្ត ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

# ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

- I-ផែនការងារធនធានមនុស្ស
  - ១-ការិ.បុគ្គលិក
  - ២-ការិ.បណ្តុះបណ្តាល
  - ៣-ការិ.ផ្សព្វផ្សាយអប់រំ
- II- ផែនការងារសេនាធិការ
  - ១-ការិ.រដ្ឋបាល
  - ២-ការិ.សរុប ផែនការ
  - ៣-ការិ.វិទ្យុទាក់ទង
  - ៤-ការិ.អក្សរសម្ងាត់
  - ៥-ការិ.កិច្ចការប៉ុ.ន.រដ្ឋបាល
  - ៦-ការិ.អន្តរាគមន៍ និងតម្រួតបទបញ្ជា
- III- ផែនការងារន.បព្រហ្មទណ្ឌ
  - ១-ការិ.នប.ព្រហ្មទណ្ឌកម្រិតធ្ងន់
  - ២-ការិ.នប.ព្រហ្មទណ្ឌកម្រិតស្រាល
  - ៣-ការិ.នប.បច្ចេកទេស និងវិទ្យាសាស្ត្រ
- IV-ផែនការងារន.បប្រឆាំងបទល្មើសសេដ្ឋកិច្ច
  - ការិ.ន.បប្រឆាំងបទល្មើសសេដ្ឋកិច្ច
- V-ផែនការងារប្រឆាំងគ្រឿងញៀន
  - ការិ.ប្រឆាំងគ្រឿងញៀន
- VI-ផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រ
  - ការិ.ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- VII-ផែនការងារសន្តិសុខ
  - ១-ការិ.សន្តិសុខផ្ទៃក្នុង
  - ២-ការិ.ប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន
  - ៣-ការិ.គ្រប់គ្រងសន្តិសុខឯកជន
  - ៤-ការិ.ប្រឆាំងបទល្មើសបច្ចេកវិទ្យា
- VIII-ផែនការងារន.បសណ្តាប់ធ្នាប់
  - ១-ការិ.ន.បសណ្តាប់ធ្នាប់
  - ២-ការិ.ន.បទេសចរណ៍
  - ៣-ការិ.ន.បការពារបេតិកភណ្ឌ
- IX-ផែនការងារន.បចរាចរណ៍
  - ១-ការិ.ន.បចរាចរណ៍ផ្លូវគោក
  - ២-ការិ.ន.បចរាចរណ៍ផ្លូវទឹក
- X-ផែនការងារគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងអគ្គិភ័យ
  - ១-ការិ.ន.បបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ
  - ២-ការិ.គ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងជាតិពុល
- XI-ផែនការងារអន្តោប្រវេសន៍
  - ១-ការិ.គ្រប់គ្រងជនបរទេស
  - ២-ការិ.ស៊ើបអង្កេតនិងអនុវត្តនីតិវិធី
- XII-ផែនការងារអត្តសញ្ញាណកម្ម
  - ១-ការិ.គ្រប់គ្រងការស្នាក់នៅ
  - ២-ការិ.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- XIII-ផែនការងារភស្តុភារ និងហិរញ្ញវត្ថុ
  - ១-ការិ.ភស្តុភារ
  - ២-ការិ.គណនេយ្យ
  - ៣-ការិ.សុខាភិបាល

អធិការដ្ឋានន.បខណ្ឌ

ប៉ុស្តិ៍ន.បរដ្ឋបាលសង្កាត់

ឧបសម្ព័ន្ធនៃប្រកាសលេខ ៦៤៤៥ ប្រ.ក
ចុះថ្ងៃ ... ខែ ... ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៨
ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

# ស្នងការដ្ឋាននគរបាលខេត្ត

- I-ផែនការងារធនធានមនុស្ស
  - ១-ការិ.បុគ្គលិក
  - ២-ការិ.បណ្តុះបណ្តាល
  - ៣-ការិ.ផ្សព្វផ្សាយអប់រំ
- II- ផែនការងារសេនាធិការ
  - ១-ការិ.រដ្ឋបាល
  - ២-ការិ.សរុប ផែនការ
  - ៣-ការិ.វិទ្យុទាក់ទង
  - ៤-ការិ.អក្សរសម្ងាត់
  - ៥-ការិ.កិច្ចការប៉ុ.ន.បរដ្ឋបាល
  - ៦-ការិ.អន្តរាគមន៍និងតម្រូតបទបញ្ជា
- III- ផែនការងារន.បព្រហ្មទណ្ឌ
  - ១-ការិ.នប.ព្រហ្មទណ្ឌកម្រិតធ្ងន់
  - ២-ការិ.នប.ព្រហ្មទណ្ឌកម្រិតស្រាល
  - ៣-ការិ.នប.បច្ចេកទេស និងវិទ្យាសាស្ត្រ
- IV-ផែនការងារន.បប្រឆាំងបទល្មើសសេដ្ឋកិច្ច
  - ការិ.ន.បប្រឆាំងបទល្មើសសេដ្ឋកិច្ច
- V-ផែនការងារប្រឆាំងគ្រឿងញៀន
  - ការិ.ប្រឆាំងគ្រឿងញៀន
- VI-ផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រ
  - ការិ.ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- VII-ផែនការងារសន្តិសុខ
  - ១-ការិ.សន្តិសុខផ្ទៃក្នុង
  - ២-ការិ.ប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន
  - ៣-ការិ.គ្រប់គ្រងសន្តិសុខឯកជន
  - ៤-ការិ.ប្រឆាំងបទល្មើសបច្ចេកវិទ្យា
  - ៥-ការិ.អង្គរក្ស
- VIII-ផែនការងារន.បសណ្តាប់ធ្នាប់
  - ១-ការិ.ន.បសណ្តាប់ធ្នាប់
  - ២-ការិ.ន.បទេសចរណ៍
  - ៣-ការិ.ន.បការពារបេតិកភណ្ឌ
  - ៤-ការិ.ន.បចរាចរណ៍ផ្លូវគោក
  - ៥-ការិ.ន.បចរាចរណ៍ផ្លូវទឹក
- IX-ផែនការងារគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងអគ្គិភ័យ
  - ១-ការិ.ន.បបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ
  - ២-ការិ.គ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងជាតិពុល
- X-ផែនការងារអន្តោប្រវេសន៍
  - ១-ការិ.គ្រប់គ្រងជនបរទេស
  - ២-ការិ.ស៊ើបអង្កេតនិងអនុវត្តនីតិវិធី
- XI-ផែនការងារអត្តសញ្ញាណកម្ម
  - ១-ការិ.គ្រប់គ្រងការស្នាក់នៅ
  - ២-ការិ.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- XII-ផែនការងារភស្តុភារ និងហិរញ្ញវត្ថុ
  - ១-ការិ.ភស្តុភារ
  - ២-ការិ.គណនេយ្យ
  - ៣-ការិ.សុខាភិបាល
- XIII-ផែនន.បការពារព្រំដែនគោក
- អធិការដ្ឋានន.បក្រុង ស្រុក
  - ប៉ុស្តិ៍ន.បរដ្ឋបាលឃុំ សង្កាត់